# ច្បាប់

## ស្តីពី

## ប្រាក់បញ្ញើ

រ ដ្ឋ ក ម្ពុ ជា
ឯករាជ្យ សន្តិភាព សេរីភាព សុភមង្គល
១១១១១

ក្រុមប្រឹក្សារដ្ឋ

លេខ: ០៧ ក្រ

# ក្រ ឹ ត្យ

## ក្រុមប្រឹក្សារដ្ឋ

## នៃ

## រដ្ឋកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃ រដ្ឋកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំរដ្ឋសភា និង ក្រុមប្រឹក្សារដ្ឋ នៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ដែលប្រកាសអោយប្រើតាមក្រឹត្យលេខ ០៤ ក្រ ចុះថ្ងៃទី ១០ ខែ កុម្ភៈ ឆ្នាំ ១៩៨២

## សំរេច

ប្រកាសអោយប្រើ ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ដែលរដ្ឋសភានៃរដ្ឋកម្ពុជាបានអនុម័ត នៅថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៣ នាសម័យប្រជុំលើកទី ២៤ នីតិកាលទី ១ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣
ជ.ក្រុមប្រឹក្សារដ្ឋ
ប្រធាន
ហត្ថលេខា និង ត្រា : ហេង សំរិន

កន្លែងទទួល:

- ខុទ្ទកាល័យគណៈកម្មាធិការកណ្តាល គណបក្សប្រជាជនកម្ពុជា
- ខុទ្ទកាល័យរដ្ឋសភា
- ខុទ្ទកាល័យក្រុមប្រឹក្សារដ្ឋមន្ត្រី
- គ្រប់ទីស្តីការរដ្ឋមន្ត្រីនិងស្ថាប័នថ្នាក់ប្រហាក់ប្រហែល
- គ្រប់គណៈកម្មាធិការប្រជាជនខេត្ត ក្រុង
- រដ្ឋកិច្ច
- កាលប្បវត្តិ - ឯកសារ

ដើម្បីចម្លងចែក
[illegible]ធិការក្រុមប្រឹក្សារដ្ឋ

ចាន់ វ៉េន

# ច្បាប់
## ស្តីពី
## ប្រាក់ប្រដាប់ក្តី

### ជំពូកទី ១
### បទបញ្ញត្តិទូទៅ

មាត្រា ១ : ត្រូវបង្កើតអោយមានប្រាក់ប្រដាប់ក្តីក្នុងកិច្ចការតុលាការ ដើម្បីផលប្រយោជន៍នៃថវិការដ្ឋ ។

មាត្រា ២ : ប្រាក់ប្រដាប់ក្តីនេះ ត្រូវចៅក្រមកំណត់នៅខាងក្រោយបង្អស់នៃសាលក្រម ឬ សាលដីការ ដោយអនុលោមតាមបទបញ្ញត្តិនៃច្បាប់នេះ ។

### ជំពូកទី ២
### ប្រាក់ប្រដាប់ក្តី

មាត្រា ៣ : ប្រាក់ប្រដាប់ក្តី គឺជាពន្ធសរុប និង ប្រាក់ចំណាយផ្សេងៗ ដែលត្រូវបង់ក្នុងរឿងក្តីនីមួយៗ ដែលបានចុះបញ្ជីនៅសាលាជំរះក្តីនៃរដ្ឋកម្ពុជា ។

ប្រាក់ប្រដាប់ក្តីត្រូវបង់ក្នុងរឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម វិវាទការងារ និង វិវាទរដ្ឋបាល ។ ប្រាក់នេះត្រូវចុងក្តីជាដើមបណ្តឹងបង់មុនជាផរាប ។ ប្រាក់នេះ ត្រូវជាបន្ទុកនៃចុងក្តីណាដែលចាញ់ក្តីនៅចុងក្រោយបង្អស់ ។

ក្នុងរឿងក្តីដែលក្រុមអយ្យការតាំងខ្លួនជាចុងក្តីដើម ត្រូវរដ្ឋបង់ប្រាក់ប្រដាប់ក្តីជាមុន ហើយប្រាក់នេះត្រូវទារពីចុងក្តីណាដែលចាញ់ក្តី តាមកំរិតដែលកំណត់ក្នុងសាលក្រម ឬ សាលដីកា ។

ក្នុងករណីណាក៏ដោយ ក្រុមអយ្យការពុំត្រូវសងប្រាក់ប្រដាប់ក្តីទៅចុងក្តីឯទៀតដែលបានបង់ហើយនោះទេ ទោះបីក្រុមអយ្យការជាចុងក្តីដើមត្រូវចាញ់ក្តីក៏ដោយ ។

ក្រុមអយ្យការគ្រាន់តែជាចុងក្តីរណប ត្រូវរួចពីការបង់ប្រាក់ប្រដាប់ក្តី ។

មាត្រា ៤ : ប្រាក់ប្រដាប់ក្តីក្នុងរឿងរដ្ឋប្បវេណី រឿងពាណិជ្ជកម្ម វិវាទការងារ និង វិវាទរដ្ឋបាល មានដូចតទៅ ៖

- ពន្ធចុះបញ្ជីក្តី
- ពន្ធជំរះក្តី
- ប្រាក់ចំណាយក្នុងកិច្ចស៊ើបសួរ
- ពន្ធចុះបញ្ជីប្រដាប់ត្រា

### ជំពូកទី ៣
### ពន្ធចុះបញ្ជីក្តី

មាត្រា ៥ : ពន្ធចុះបញ្ជីក្តី គឺជាពន្ធដែលត្រូវទារយកនៅពេលចុះបញ្ជីក្តី នៅសាលាជំរះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីអោយសាលាជំរះក្តី យករឿងរបស់ខ្លួនចុះបញ្ជីជំនុំជំរះ ។ ប្រាក់នេះមិនបង្វិលអោយដើមបណ្តឹងវិញទេ

នោះបីរឿងក្តីនោះត្រូវចំណាយចេញពីបញ្ជីក្តីមុនសាលក្រម ឬសាលដីកាសំរេចសេចក្តីជាស្ថាពរក៏ដោយ ។ ដើមបណ្តឹងត្រូវបង់ប្រាក់ពន្ធនេះទៅការិយាល័យក្រឡាបញ្ជី ។

__មាត្រា ៦__ : ប្រាក់ពន្ធនេះតម្រូវឱ្យគូក្តីនោះបង់ជាថ្មីទៀតដែរ បើមានគូក្តីណាមួយបានដាក់ពាក្យស្នើសុំអោយតុលាការចេញដីកាសំរេចជាកិច្ចការប្រញាប់ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ។

__មាត្រា ៨__ : អត្រាពន្ធចុះបញ្ជីក្តី ត្រូវកំណត់ដូចតទៅ ៖

- __តុលាការខេត្តក្រុង__
- រឿងរដ្ឋប្បវេណី មួយពាន់រៀល " ១,០០០ ៛ ០០ "
- រឿងពាណិជ្ជកម្ម មួយពាន់រៀល " ១,០០០ ៛ ០០ "
- វិវាទការងារ មួយពាន់រៀល " ១,០០០ ៛ ០០ "
- វិវាទរដ្ឋបាល មួយពាន់រៀល " ១,០០០ ៛ ០០ "
- __សាលាឧទ្ធរណ៍__
- រឿងរដ្ឋប្បវេណី មួយពាន់ប្រាំរយរៀល " ១,៥០០ ៛ ០០ "
- រឿងពាណិជ្ជកម្ម មួយពាន់ប្រាំរយរៀល " ១,៥០០ ៛ ០០ "
- វិវាទការងារ មួយពាន់ប្រាំរយរៀល " ១,៥០០ ៛ ០០ "
- វិវាទរដ្ឋបាល មួយពាន់ប្រាំរយរៀល " ១,៥០០ ៛ ០០ "
- __តុលាការកំពូល__
- រឿងរដ្ឋប្បវេណី ពីរពាន់រៀល " ២,០០០ ៛ ០០ "
- រឿងពាណិជ្ជកម្ម ពីរពាន់រៀល " ២,០០០ ៛ ០០ "
- វិវាទការងារ ពីរពាន់រៀល " ២,០០០ ៛ ០០ "
- វិវាទរដ្ឋបាល ពីរពាន់រៀល " ២,០០០ ៛ ០០ "

ប្រាក់នេះត្រូវដក ១០ ភាគរយ នៅតុលាការខេត្ត.ក្រុង ១៥ ភាគរយ នៅសាលាឧទ្ធរណ៍ ២០ ភាគរយ នៅតុលាការកំពូល ជាប្រយោជន៍ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

## __ជំពូកទី ៤__

## __ពន្ធជំរះក្តី__

I- __ពន្ធនឹង__ :

__មាត្រា ៨__ : ពន្ធនឹង គឺជាប្រាក់ពន្ធដែលត្រូវយកលើការជំរះក្តីនីមួយៗ ។ ប្រាក់ពន្ធនេះ ត្រូវបង្វិលឱ្យដើមបណ្តឹងវិញ បើតុលាការបានសំរេចចំណាយរឿងក្តីនោះចោល ។ ប្រាក់នេះត្រូវដើមបណ្តឹងបង់ជាមួយនឹងពន្ធចុះបញ្ជីក្តី ។

ប្រាក់នេះត្រូវដាក់ចូលថវិការដ្ឋ ក្រោយដែលតុលាការ បានសំរេចចេញសាលក្រម ឬ សាលដីកា ទោះបីជាមានការប្តឹងតវ៉ាក៏ដោយ ។

__មាត្រា ៩__ : ពន្ធនេះ ត្រូវអោយគូក្តីបង់ជាថ្មីដែរ បើគូក្តីណាមួយបានដាក់ពាក្យស្នើសុំអោយតុលាការចេញ

ដីកាជាកិច្ចការប្រញាប់ ដើម្បីការពារផលប្រយោជន៍របស់ខ្លួន ហើយត្រូវបង់ពន្ធជាមួយគ្នានិងពន្ធចុះបញ្ជីក្តីដូចមានចែងក្នុងមាត្រា ៦ ខាងលើ ។

<u>មាត្រា ១០</u> : អត្រាពន្ធនឹងត្រូវកំណត់ដូចតទៅ ៖

- <u>**តុលាការខេត្តក្រុង**</u>
- រឿងរដ្ឋប្បវេណី មួយពាន់រៀល " ១,០០០ ៛ ០០ "
- រឿងពាណិជ្ជកម្ម មួយពាន់រៀល " ១,០០០ ៛ ០០ "
- វិវាទការងារ មួយពាន់រៀល " ១,០០០ ៛ ០០ "
- វិវាទរដ្ឋបាល មួយពាន់រៀល " ១,០០០ ៛ ០០ "
- <u>**សាលាឧទ្ធរណ៍**</u>
- រឿងរដ្ឋប្បវេណី មួយពាន់ប្រាំរយរៀល " ១,៥០០ ៛ ០០ "
- រឿងពាណិជ្ជកម្ម មួយពាន់ប្រាំរយរៀល " ១,៥០០ ៛ ០០ "
- វិវាទការងារ មួយពាន់ប្រាំរយរៀល " ១,៥០០ ៛ ០០ "
- វិវាទរដ្ឋបាល មួយពាន់ប្រាំរយរៀល " ១,៥០០ ៛ ០០ "
- <u>**តុលាការកំពូល**</u>
- រឿងរដ្ឋប្បវេណី ពីរពាន់រៀល " ២,០០០ ៛ ០០ "
- រឿងពាណិជ្ជកម្ម ពីរពាន់រៀល " ២,០០០ ៛ ០០ "
- វិវាទការងារ ពីរពាន់រៀល " ២,០០០ ៛ ០០ "
- វិវាទរដ្ឋបាល ពីរពាន់រៀល " ២,០០០ ៛ ០០ "

ប្រាក់នេះត្រូវដក ១០ ភាគរយ នៅតុលាការខេត្ត.ក្រុង ១៥ ភាគរយ នៅសាលាឧទ្ធរណ៍ ២០ ភាគរយ នៅតុលាការកំពូលជាប្រយោជន៍ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

## I - <u>ពន្ធសមាមាត្រ</u> :

<u>មាត្រា ១១</u> : ពន្ធសមាមាត្រនៃការជំរះក្តី គឺជាពន្ធដែលគិតយកលើតម្លៃដែលតុលាការបានសំរេចអោយភាគីម្ខាងប្រគល់ទៅអោយភាគីម្ខាងទៀត ។ ប្រាក់នេះមិនត្រូវបង់ទុកជាមុនទេ ។

ប្រាក់នេះត្រូវអោយបង់តែមួយដងនៅវេលាដែលចេញសេចក្តីចម្លងសាលក្រម ឬ សាលដីកាដែលបានសំរេចសេចក្តីជាស្រេចដាច់ខាត ហើយផុតអំណាចប្តឹងតវ៉ា ។

<u>មាត្រា ១២</u> : ពន្ធសមាមាត្រ នេះត្រូវគិតយកមួយភាគរយលើទឹកប្រាក់ ដែលតុលាការបានសំរេចប្រគល់អោយម្ចាស់វិញ ។

ប្រាក់ដែលបានមកពីពន្ធសមាមាត្រនេះ ត្រូវបង់ចូលថវិការដ្ឋ ៨០ ភាគរយ និង ២០ ភាគរយត្រូវដាក់ចូលក្នុងហិបក្រឡាបញ្ជីទូទាំងរដ្ឋកម្ពុជា ។

<u>មាត្រា ១៣</u> : កូនក្តីត្រូវបង់ប្រាក់ពន្ធសមាមាត្រនេះក្នុងកំណត់ ៤ ខែគត់ គិតពីថ្ងៃទទួលដីកាបង្គាប់អោយបង់ប្រាក់នេះ តាមដីកាបង្គាប់ដែលប្រធានតុលាការចុះហត្ថលេខា ។ ក្នុងករណីយឺតយ៉ាវមិនបានបង់

ប្រាក់ពន្ធនេះតាមការកំណត់ ត្រូវពិន័យទ្វេរមួយជាពីរ ។

## ជំពូកទី ៥

## ប្រាក់ចំណាយក្នុងការស៊ើបសួរ

**មាត្រា ១៤** : ប្រាក់ចំណាយផ្សេងៗក្នុងកិច្ចស៊ើបសួរ ហៅថាប្រាក់បំរុងទុក ដែលសំរាប់ចំណាយទៅលើការប្រគល់ដីកាកោះ ទៅលើសាក្សីទៅលើអាជ្ញាកណ្តាល ទៅលើកោសល្យវិច័យ ទៅលើអាជ្ញាធរតុលាការដែលបានទៅពិនិត្យដល់ទីកន្លែង ។

**មាត្រា ១៥** : ប្រាក់នេះត្រូវដើមបណ្តឹងបង់ជាមួយនិងពន្ធចុះបញ្ជី ។ ហើយបើមិនបានចំណាយអ្វីទេ ឬនៅសល់ ត្រូវតែប្រគល់ទៅឱ្យដើមបណ្តឹងវិញ ។ ប៉ុន្តែបើប្រាក់នោះចាយមិនគ្រប់គ្រាប់ នោះប្រធានតុលាការ អាចនឹងចេញដីកាបង្គាប់អោយដើមបណ្តឹងបង់បន្ថែមជាថ្មីទៀតបាន ។

**មាត្រា ១៦** : ប្រាក់បំរុងទុកនេះ ត្រូវកំណត់អោយបង់ជាដំបូងតទៅទៀត ៖

- **តុលាការខេត្តក្រុង**

| | | |
|---|---|---|
| - រឿងរដ្ឋប្បវេណី | ប្រាំពាន់រៀល | " ៥,000 ៛ 00 " |
| - រឿងពាណិជ្ជកម្ម | ប្រាំពាន់រៀល | " ៥,000 ៛ 00 " |
| - វិវាទការងារ | ប្រាំពាន់រៀល | " ៥,000 ៛ 00 " |
| - វិវាទរដ្ឋបាល | ប្រាំពាន់រៀល | " ៥,000 ៛ 00 " |

- **សាលាឧទ្ធរណ៍**

| | | |
|---|---|---|
| - រឿងរដ្ឋប្បវេណី | មួយម៉ឺនរៀល | " ១០,000 ៛ 00 " |
| - រឿងពាណិជ្ជកម្ម | មួយម៉ឺនរៀល | " ១០,000 ៛ 00 " |
| - វិវាទការងារ | មួយម៉ឺនរៀល | " ១០,000 ៛ 00 " |
| - វិវាទរដ្ឋបាល | មួយម៉ឺនរៀល | " ១០,000 ៛ 00 " |

- **តុលាការកំពូល**

| | | |
|---|---|---|
| - រឿងប្បវេណី | មួយម៉ឺនប្រាំពាន់រៀល | " ១៥,000 ៛ 00 " |
| - រឿងពាណិជ្ជកម្ម | មួយម៉ឺនប្រាំពាន់រៀល | " ១៥,000 ៛ 00 " |
| - វិវាទការងារ | មួយម៉ឺនប្រាំពាន់រៀល | " ១៥,000 ៛ 00 " |
| - វិវាទរដ្ឋបាល | មួយម៉ឺនប្រាំពាន់រៀល | " ១៥,000 ៛ 00 " |

## ជំពូកទី ៦

## ពន្ធចុះបញ្ជីប្រថាប់ត្រា

**មាត្រា ១៧** : គ្រប់លិខិតដែលកូនក្តីបានយកមកបញ្ចូលក្នុងសុំណុំរឿង ត្រូវចុះបញ្ជីប្រថាប់ត្រា និងបិទតែមប្រិយ៍ នៅពេលដែលកូនក្តី បានយកមកដាក់ក្នុងសំណុំរឿង ជាទុកជាសំអាងនៃសិទ្ធិរឿងៗខ្លួន ។

សេចក្តីចម្លងសាលក្រម ឬ សាលដីកាទាំងមូល និងសំរាប់សាលក្រម ឬ សាលដីកា ត្រូវអោយបិទតែមប្រិយ៍ លើកលែងតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងក្រសួងក្រុមអយ្យការសុំ ។

ក ម្ពុ ជា

ទីស្តីការក្រសួងយុត្តិធម៌

លេខ : ០៣ សរ ៩៣ ភ្នំពេញ, ថ្ងៃទី ២០ ខែ សីហា ឆ្នាំ ១៩៩៣

## ស ា រ ា ច រ

**រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

**សូមជំរាបមក**

ឯកឧត្តម ប្រធានតុលាការកំពូល
ឯកឧត្តម អគ្គរដ្ឋអាជ្ញាអមតុលាការកំពូល
លោក ប្រធានសាលាឧទ្ធរណ៍
លោក អគ្គរដ្ឋអាជ្ញាអមសាលាឧទ្ធរណ៍
លោក រដ្ឋអាជ្ញាអមតុលាការខេត្ត-ក្រុង
លោក ប្រធានតុលាការយោធា
លោក រដ្ឋអាជ្ញាអមតុលាការយោធា

**កម្មវត្ថុ** : ការអនុវត្តន៍ច្បាប់ ស្តីពីប្រាក់ប្រដាប់ក្តី ។

ខ្ញុំសូមជំរាបថា ច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ត្រូវបានប្រកាសអោយប្រើរួចហើយ ។ ក្រោយពីច្បាប់នេះត្រូវបានប្រកាសអោយប្រើតុលាការខេត្ត-ក្រុង បានទទួលការណែនាំផ្ទាល់ពីក្រសួងអំពីបែបបទសំរាប់អនុវត្តរួចហើយដែរ ។ ក្រសួងយុត្តិធម៌មានជំនឿថា តុលាការខេត្ត-ក្រុង ប្រាកដជាអនុវត្តបានល្អហើយ ។ ដើម្បីបញ្ជាក់អោយបានយល់រឹតតែច្បាស់ ឥឡូវនេះ ក្រសួងសូមណែនាំ និងរំលឹកឡើងវិញនូវប្រការមួយចំនួនដែលត្រូវប្រតិបត្តិដូចតទៅ :

**អំពីការបង់ប្រាក់ប្រដាប់ក្តី នៅតុលាការខេត្ត-ក្រុង**

ក្នុងរឿងរដ្ឋប្បវេណី ពាណិជ្ជកម្ម វិវាទរដ្ឋបាល និង វិវាទការងារ តាមនីតិវិធី តុលាការត្រូវធ្វើការផ្សះផ្សាសិន ក្នុងករណីគូក្តីមិនសះជាគ្នាទេ ទើបអោយគូក្តីបង់ប្រាក់ប្រដាប់ក្តីតាមច្បាប់ គឺចាប់ពីពេលនោះហើយ ដែលតុលាការមានអំណាចធ្វើអង្កេត និងដាក់រឿងជំនុំជំរះបាន ។ តែបើអ្នកប្តឹងមិនបានបង់ប្រាក់ប្រដាប់ក្តីទេ តុលាការគ្មានអំណាចចាត់ការ និងដាក់រឿងជំនុំជំរះបានទេ លើកលែងតែក្នុងករណីដែលបានទទួលការអនុគ្រោះ ពីតុលាការនៅក្នុងលក្ខខណ្ឌដែលច្បាប់បានកំណត់ ។

ក្នុងករណីរឿងអង្គសេចក្តីដែលមានទំនាក់ទំនងនឹងកិច្ចការប្រញាប់ គូក្តីអាចស្នើសុំបង់ប្រាក់ប្រដាប់ក្តីភ្លាមៗបានដែរ នៅពេលគេដាក់ពាក្យបណ្តឹង ។ ឯការផ្សះផ្សាវិញ ត្រូវធ្វើតាមនីតិវិធីដដែលឥតបញ្ឈប់ទេ ។

ដើមបណ្តឹងត្រូវបង់ប្រាក់ប្រដាប់ក្តីជាដំបូង ៧,០០០ រៀល ។ ប្រាក់នេះ ត្រូវដើមបណ្តឹងបង់នៅក្រឡាបញ្ជីកាន់ហិបប្រាក់ ។ ក្រឡាបញ្ជីកាន់ហិបប្រាក់ត្រូវចេញបង្កាន់ដៃទៅអោយអ្នកបង់ ។ នីតិវិធីទូទាត់ចំណាយប្រាក់នេះមានដូចតទៅ :

## ពន្ធចុះបញ្ជីក្តី

នៅពេលចុះបញ្ជីក្តី នៅក្នុងសៀវភៅដែលមានលេខ....... ថ្ងៃ .... ខែ ...... ឆ្នាំ........... សំណុំរឿងចុះឈ្មោះគូក្តី និង កម្មវត្ថុនៃបណ្តឹងក្រឡាបញ្ជីកាន់ហិបប្រាក់ ត្រូវកាត់យកពន្ធចុះបញ្ជីក្តីជាប្រាក់ ចំនួន ១.០០០ រៀល ។ ក្នុងប្រាក់នេះ ត្រូវយកទៅឃ្លាំងចំនួន ៩០០ រៀល និងបានជាប្រយោជន៍ក្រឡាបញ្ជីកាន់ហិបប្រាក់ ១០០ រៀល ។

ចំពោះពន្ធចុះបញ្ជីក្តីនេះ មិនត្រូវបង្វិលអោយដើមបណ្តឹងវិញទេ ទោះជាតុលាការបានចំណាយរឿងនេះចោលក៏ដោយ ។ ក្រឡាបញ្ជីកាន់ហិបប្រាក់ត្រូវតែធ្វើបញ្ជីទូទាត់ពន្ធចុះបញ្ជីក្តីដែលត្រូវដាក់ឃ្លាំង និង ត្រូវបានជាប្រយោជន៍ក្រឡាបញ្ជីដោយខានមិនបាន នៅដំណាច់ខែនីមួយៗ ដោយមិនចាំបាច់រង់ចាំសេចក្តីរបស់តុលាការទេ ។

ជារៀងរាល់ខែក្រឡាបញ្ជីក៏ត្រូវធ្វើបញ្ជីនេះ ជូនមកក្រសួងយុត្តិធម៌មួយច្បាប់ផងដែរ ដើម្បីក្រសួងយុត្តិធម៌ត្រួតពិនិត្យ និង តាមដានអំពីសកម្មភាពទាំងនោះ ។

## ពន្ធជំរះក្តី

**ពន្ធជំរះក្តីត្រូវបានចែកជាពីរ គឺ :**

**១. ពន្ធហ្នឹង " មិនប្រែប្រួល "**

**២. ពន្ធសមាមាត្រ**

- ចំពោះពន្ធហ្នឹង ជាគោលការណ៍ត្រូវទូទាត់កាត់យកក្នុងប្រាក់ប្រដាប់ក្តីដែលបានបង់ជាដំបូងនោះ ប៉ុន្តែអាចនឹងទូទាត់បានលុះត្រាតែតុលាការបានសំរេចសេចក្តីហើយសិន ។ ដោយឡែកប្រាក់នេះត្រូវបង្វិលអោយដើមបណ្តឹងវិញ ក្នុងករណីដែលតុលាការបានចំណាយរឿងចោល ។ តែបើតុលាការបានសំរេចក្រៅពីចំណាយរឿងចោល ទោះជាមានបណ្តឹងតវ៉ាក្តី ឬ គ្មានបណ្តឹងតវ៉ាក្តី ក្រោយពីតុលាការបានសំរេចសេចក្តីហើយ ក្រឡាបញ្ជីត្រូវធ្វើបញ្ជីទូទាត់ពន្ធហ្នឹងនេះ ដោយយកទៅដាក់ឃ្លាំងចំនួន ៩០០ រៀល និងបានជាប្រយោជន៍ក្រឡាបញ្ជីកាន់ហិបប្រាក់ ១០០រៀល នៅក្នុងដំណាច់ខែនីមួយៗ ដូចគ្នានិងពន្ធចុះបញ្ជីក្តីដែរ ។ បញ្ជីទូទាត់ប្រាក់ពន្ធហ្នឹងនេះ ត្រូវផ្ញើជូនមកក្រសួងយុត្តិធម៌មួយច្បាប់ជារៀងរាល់ខែ ដើម្បីអោយក្រសួងពិនិត្យ ។

- ចំពោះពន្ធសមាមាត្រវិញ មិនត្រូវឱ្យគូក្តីបង់ទុកជាមុនទេ ហើយក៏មិនត្រូវកាត់ទូទាត់ជាមួយនឹងប្រាក់ប្រដាប់ក្តីដែលបង់ជាដំបូងនោះដែរ ។ ប្រាក់នេះអាចទូទាត់បានលុះត្រាតែសាលក្រមមានអនុភាពអនុវត្ត ហើយដែលត្រូវបង្គាប់អោយគូក្តីបង់ គឺនៅពេលដែលគូក្តីនោះ សុំចម្លងសាលក្រមយកទៅអនុវត្ត ។ ប្រសិនបើគូក្តីមិនព្រមបង់ពន្ធសមាមាត្រនេះទេ ក្រឡាបញ្ជីមិនត្រូវចេញសេចក្តីចម្លងសាលក្រមអោយទៅគូក្តីឡើយ ។

ពន្ធសមាមាត្រនេះ បើបង់នៅខែណា ក្រឡាបញ្ជីត្រូវធ្វើបញ្ជីទូទាត់នៅក្នុងខែនោះ ដោយត្រូវញែកដាក់ឃ្លាំង ៨០ ភាគរយ និងដាក់ក្នុងហិបប្រាក់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយ ។

ក្រឡាបញ្ជីកាន់ហិបប្រាក់មិនអាចដកយកពន្ធសមាមាត្រនេះជាប្រយោជន៍របស់ខ្លួន ដូចជាពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងបានឡើយ ។

បញ្ជីទូទាត់ពន្ធសមាមាត្រនេះ ត្រូវផ្ញើជូនមកក្រសួងយុត្តិធម៌ជារៀងរាល់ខែដែរ ដើម្បីក្រសួងមាន លទ្ធភាពត្រួតពិនិត្យ ។

**អំពីប្រាក់ចំណាយក្នុងកិច្ចស៊ើបសួរ**

ប្រាក់ចំណាយក្នុងកិច្ចស៊ើបសួរ ជាគោលការណ៍ត្រូវដកយកពីប្រាក់ប្រដាប់ក្ដី ដែលបានបង់ជាដំបូង នោះ ។ ហើយអាចដកចំណាយបានតែទៅលើការប្រគល់ដីកានោះ ទៅលើសាក្សី ទៅលើអាជ្ញាកណ្ដាល ទៅលើកោសល្យវិច័យ និងទៅលើអាជ្ញាធរតុលាការដែលបានទៅពិនិត្យដល់ទីកន្លែងតែប៉ុណ្ណោះ ។ ក្រៅពីនេះ ពុំអាចដកយកទៅចាយបានទេ ។

ក្នុងប្រាក់ដែលបានបង់ជាដំបូងនេះ បើចាយមិនអស់ ត្រូវប្រគល់អោយដើមបណ្ដឹងវិញ តែបើការ ចំណាយមានចំនួនច្រើនលើសពីប្រាក់ដែលគេបង់ ក្រឡាបញ្ជីដែលទទួលកិច្ចការនេះ ត្រូវបង្គាប់អោយគូក្ដីបង់ បន្ថែមអោយបានមុនតុលាការជំនុំជំរះ ។

- ការចំណាយទៅលើអាជ្ញាកណ្ដាល ទៅលើកោសល្យវិច័យ ទៅលើអាជ្ញាធរតុលាការដែលបាន ទៅពិនិត្យដល់ទីកន្លែង លុះណាតែមានដីកា ឬ សាលក្រមរបៀបរបស់តុលាការចាត់អោយធ្វើ ទើបអ្នក ទាំងនោះមានសិទ្ធិដកយកប្រាក់ចំណាយនេះបាន ។ ប្រសិនបើគ្មានទេអ្នកទាំងនោះ គ្មានសិទ្ធិដកយកប្រាក់ នេះបានទេ ។

- ឯការចំណាយទៅលើដីកាកោះ និងលើសាក្សីវិញ នឹងអាចធ្វើទៅបានលុះណាតែអ្នកប្រគល់ ដីកាកោះបានប្រគល់ដីកាកោះនោះដល់ទីកន្លែង ឬទីលំនៅរបស់គេ រីឯសាក្សីវិញ លុះណាតែសាក្សីនោះ ចូលមកចំពោះមុខតុលាការតាមការអញ្ជើញ ទើបអ្នកទាំងនោះមានសិទ្ធិដកយកប្រាក់ខាងលើនេះបាន ។

**អំពីការបង់ប្រដាប់ក្ដីនៅសាលាឧទ្ធរណ៍ និង តុលាការកំពូល**

ជាគោលការណ៍ នៅសាលាឧទ្ធរណ៍ និង តុលាការកំពូល ក្រោយពីបានទទួលសំណុំរឿង ក្រឡាបញ្ជីទទួលបន្ទុកត្រូវអញ្ជើញអ្នកប្ដឹងឧទ្ធរណ៍ ឬប្ដឹងសាទុក្ខ អោយមកបង់ប្រាក់ប្រដាប់ក្ដីនៅការិយាល័យ ក្រឡាបញ្ជីនៃសាលានីមួយ ៗ គឺ :

១- សាលាឧទ្ធរណ៍បង់ជាដំបូង ១៣.០០០ រៀល

២- តុលាការកំពូលបង់ជាដំបូង ១៩.០០០ រៀល

ឯការដកចំណាយក៏ត្រូវអនុវត្តដូចគ្នា និង តុលាការខេត្ត-ក្រុងដែរ គ្រាន់តែខុសចំនួនទឹកប្រាក់ ដែលត្រូវចំណាយតែប៉ុណ្ណោះ គឺ :

**សាលាឧទ្ធរណ៍**

១- ពន្ធចុះបញ្ជីក្ដី ១.៥០០ រៀល ដោយត្រូវដាក់ឃ្លាំង ១.២៧៥ រៀល និងរង្វាន់ក្រឡាបញ្ជី កាន់ហិបប្រាក់ ២២៥ រៀល ។

២- ពន្ធហ៊ីង ១.៥០០ រៀល ដោយត្រូវដាក់ឃ្លាំង ១.២៧៥ រៀល និងរង្វាន់ក្រឡាបញ្ជីកាន់ ហិបប្រាក់ ២២៥ រៀល ។

៣- ប្រាក់បំរុង ចំនួន ១០.០០០ រៀល ។

**ឧបសម្ព័ន្ធ ការកំពូល**

១- ពន្ធចុះបញ្ជីក្តី ២.០០០ រៀល ដោយត្រូវដាក់ឃ្លាំង ១.៦០០ រៀល និងរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤០០ រៀល ។

២- ពន្ធហ៊ឺង ២.០០០ រៀល ដោយត្រូវដាក់ឃ្លាំង ១.៦០០ រៀល និងរង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ៤០០ រៀល ។

៣- ប្រាក់បំរុង ១៥.០០០ រៀល ។

ពន្ធសមាមាត្រ និងប្រាក់ចំណាយក្នុងកិច្ចស៊ើបសួរ ក៏ត្រូវអនុវត្តតាមទំរង់ការតែមួយដូចគ្នា និងតុលាការខេត្ត-ក្រុងដែរ ។

គ្រប់ការទូទាត់ចំណាយប្រាក់ប្រដាប់ក្តី ត្រូវសរសេរអោយបានច្បាស់នៅក្នុងសាលក្រម ឬសាលដីការបស់ខ្លួន ។ បើមានបាត់បង់ ឬ បានចំណាយមិនត្រឹមត្រូវ ក្រឡាបញ្ជីដែលត្រូវរក្សាប្រាក់នេះនឹងត្រូវទទួលខុសត្រូវ ដូចមានចែងក្នុងមាត្រាទី ១៩ នៃច្បាប់ស្តីពីប្រាក់ប្រដាប់ក្តី ។

ដោយឡែកប្រធានតុលាការត្រូវត្រួតពិនិត្យជាប្រចាំ អំពីសកម្មភាពរបស់ក្រឡាបញ្ជីកាន់ហិបប្រាក់ ដោយចាត់វិធានការយ៉ាងតឹងរ៉ឹង ដើម្បីគ្រប់គ្រងប្រាក់នេះអោយបានល្អ ។

ចៅក្រមណាមួយ ដែលទទួលជំនុំជំរះរឿងដោយឥតអោយគូក្តីបង់ប្រដាប់ក្តី ចៅក្រមនោះត្រូវទទួលខុសត្រូវអំពីការបាត់បង់ប្រាក់ប្រដាប់ក្តីនេះ ។

អំណើះតទៅ ក្រសួងយុត្តិធម៌នឹងចាត់អ្នកជំនាញអោយមកត្រួតពិនិត្យដល់មូលដ្ឋាន ដោយមិនអោយដឹងជាមុន ។ បើឃើញថា ការគ្រប់គ្រង និងថែរក្សាប្រាក់ប្រដាប់ក្តីប្រព្រឹត្តទៅមិនបានល្អ ក្រសួងនឹងមានវិធានការយកច្បាប់ ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃកម្ពុជា ត្រង់ជំពូកទី ៦ មកអនុវត្តលើចៅក្រម ឬ លើក្រឡាបញ្ជីខុសឆ្គង ។

អស់លោកចៅក្រម និងក្រឡាបញ្ជីទាំងអស់ ត្រូវអនុវត្តអោយបានល្អសារាចរណែនាំនេះ ដើម្បីជាប្រយោជន៍ក្នុងការពង្រឹងនីត្យានុកូលភាព ។

**រដ្ឋមន្ត្រី**

**ចែម ស្ងួន**

<u>ចម្លងជូន</u> :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- សភាជាតិ
- ក្រសួងហិរញ្ញវត្ថុ
- អភិបាលខេត្ត-ក្រុង

"<u>ដើម្បីជ្រាបជាពត៌មាន</u>